**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ១១៣៧ ព.ណ.អ.ក.ប.ប

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពន្យារពេលទទួលពាក្យស្នើសុំធ្វើជាសមាជិកគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា ដែលជាបុគ្គលឯករាជ្យសម្រាប់អាណត្តិដំបូង រហូតដល់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២

**យោង ៖** សេចក្តីជូនដំណឹងលេខ០៦៥៩ ពណ.អ.កបប ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ ស្តីពីការជ្រើសរើសសមាជិកគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា «គ.ប.ក.» ដែលជាបុគ្គលឯករាជ្យសម្រាប់អាណត្តិដំបូង។

ក្រសួងពាណិជ្ជកម្ម មានកិត្តិយស សូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ដែលមានបំណងដាក់ពាក្យស្នើសុំធ្វើជាសមាជិក គ.ប.ក. ដែលជាបុគ្គលឯករាជ្យសម្រាប់អាណត្តិដំបូង មេត្តាជ្រាបថា៖ គណៈកម្មការជ្រើសរើសសមាជិក គ.ប.ក. ដែលជាបុគ្គលឯករាជ្យសម្រាប់អាណត្តិដំបូង សូមធ្វើការពន្យារពេលការដាក់និងទទួលពាក្យរហូតដល់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ១៧:០០នាទី។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ដែលមានបំណងដាក់ពាក្យស្នើសុំធ្វើជាសមាជិកគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា ដែលជាបុគ្គលឯករាជ្យសម្រាប់អាណត្តិដំបូងអាចទំនាក់ទំនងសាកសួរព័ត៌មាន នៅអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ «ក.ប.ប.» ដែលមានអាសយដ្ឋាន ផ្លូវលេខ១៨ ភូមិក្តីតាកុយ សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឬតាមរយៈលេខទូរស័ព្ទ ០៩៨ ៨៨៩ ៨៨៩ ឬ ០៧៨ ៨៦ ៨៦ ៩៨ ។

ថ្ងៃ សុក្រ ១០ រោច ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០២២

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ០៦៥៩ ព.ណ.ស.ក.ប.ប

# សេចក្តីជូនដំណឹង
# ស្តីពី
# ការជ្រើសរើសសមាជិកគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា ដែលជាបុគ្គលឯករាជ្យសម្រាប់អាណត្តិដំបូង

គណៈកម្មការជ្រើសរើសសមាជិកគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា "គ.ប.ក." ដែលជាបុគ្គលឯករាជ្យសម្រាប់អាណត្តិដំបូង មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា គណៈកម្មការជ្រើសរើសសមាជិក គ.ប.ក. ដែលជាបុគ្គលឯករាជ្យសម្រាប់អាណត្តិដំបូង នឹងរៀបចំជ្រើសរើសសមាជិក គ.ប.ក. ដែលជាបុគ្គលឯករាជ្យសម្រាប់អាណត្តិដំបូងចំនួន ៥(ប្រាំ)រូប ដែលរួមមាន៖

- អតីតចៅក្រម ១រូប
- បុគ្គលដែលមានចំណេះដឹងនិងបទពិសោធផ្នែកច្បាប់ ២រូប
- បុគ្គលដែលមានចំណេះដឹងនិងបទពិសោធផ្នែកសេដ្ឋកិច្ច ២រូប។

បេក្ខជនដែលមានចំណាប់អារម្មណ៍ដាក់ពាក្យស្នើសុំធ្វើជាសមាជិក គ.ប.ក. ដែលជាបុគ្គលឯករាជ្យសម្រាប់អាណត្តិដំបូង ត្រូវបំពេញនូវរាល់លក្ខខណ្ឌដូចខាងក្រោម៖

## ១. លក្ខខណ្ឌនៃការដាក់ពាក្យស្នើសុំ

បេក្ខជនដាក់ពាក្យស្នើសុំធ្វើជាសមាជិក គ.ប.ក. ដែលជាបុគ្គលឯករាជ្យសម្រាប់អាណត្តិដំបូង ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ
- មានអាយុយ៉ាងតិច ៣៥(សាមសិបប្រាំ)ឆ្នាំ
- មិនដែលមានទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋណាមួយ
- មានកិត្តិយសនៅក្នុងវិជ្ជាជីវៈរបស់ខ្លួន ជាមួយបទពិសោធការងារយ៉ាងតិច ៥(ប្រាំ)ឆ្នាំ
- ត្រូវបានទទួលស្គាល់ថាមានអត្តចរិតល្អ កេរ្តិ៍ឈ្មោះល្អ ភាពស្មោះត្រង់ និងសុចរិតភាព
- មានបរិញ្ញាបត្រផ្នែកច្បាប់ ឬមានសញ្ញាបត្រកម្រិតលើសពីនេះពាក់ព័ន្ធនឹងផ្នែកច្បាប់សម្រាប់សមាជិក គ.ប.ក. ដែលជាបុគ្គលឯករាជ្យដែលមានចំណេះដឹងនិងបទពិសោធផ្នែកច្បាប់



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

- មានបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ឬមានសញ្ញាបត្រកម្រិតលើសពីនេះពាក់ព័ន្ធនឹងផ្នែកសេដ្ឋកិច្ច សម្រាប់សមាជិក គ.ប.ក. ដែលជាបុគ្គលឯករាជ្យដែលមានចំណេះដឹងនិងបទពិសោធផ្នែកសេដ្ឋកិច្ច
- មានអតីតភាពជាចៅក្រម សម្រាប់សមាជិក គ.ប.ក. ដែលជាបុគ្គលឯករាជ្យដែលជាអតីតចៅក្រម។

### ២. កាលបរិច្ឆេទនិងទីកន្លែងទទួលពាក្យស្នើសុំ

បេក្ខជនដែលមានបំណងដាក់ពាក្យស្នើសុំធ្វើជាសមាជិក គ.ប.ក. ដែលជាបុគ្គលឯករាជ្យសម្រាប់អាណត្តិដំបូង អាចមកទទួលពាក្យស្នើសុំ (ដូចមានគំរូជូនភ្ជាប់) **នៅអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ "ក.ប.ប."** រៀងរាល់ម៉ោងធ្វើការ ឬអាចទាញយកតាមរយៈគេហទំព័រ **www.ccfdg.gov.kh**។

បេក្ខជនត្រូវដាក់ពាក្យស្នើសុំដោយភ្ជាប់ជាមួយនូវឯកសារសំខាន់ៗពាក់ព័ន្ធនានា នៅអគ្គនាយកដ្ឋាន ក.ប.ប. រៀងរាល់ម៉ោងធ្វើការចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ **ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២**។

### ៣. នីតិវិធីនៃការជ្រើសរើសបេក្ខជន

បេក្ខជនដែលបានដាក់ពាក្យស្នើសុំនឹងត្រូវធ្វើការសម្រាំង ដោយផ្អែកលើចំណេះដឹង ជំនាញ បទពិសោធ និងលក្ខណសម្បត្តិគ្រប់គ្រាន់។ បេក្ខជនដែលជាប់សម្រាំងនឹងត្រូវធ្វើការប្រឡងវិញ្ញាសាផ្ទាល់មាត់។

កាលបរិច្ឆេទប្រកាសបេក្ខជនដែលជាប់សម្រាំង និងកាលបរិច្ឆេទនិងទីកន្លែងនៃការប្រឡងវិញ្ញាសាផ្ទាល់មាត់ នឹងត្រូវជូនដំណឹងដោយលេខាធិការដ្ឋាននៃគណៈកម្មការជ្រើសរើសសមាជិក គ.ប.ក. ដែលជាបុគ្គលឯករាជ្យសម្រាប់អាណត្តិដំបូង។

### ៤. អាសយដ្ឋានទំនាក់ទំនង

បេក្ខជនដែលមានបំណងដាក់ពាក្យស្នើសុំធ្វើជាសមាជិក គ.ប.ក. ដែលជាបុគ្គលឯករាជ្យសម្រាប់អាណត្តិដំបូង អាចទំនាក់ទំនងសួរព័ត៌មាននៅ**អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ "ក.ប.ប."** ដែលមានអាសយដ្ឋាន ផ្លូវលេខ១៨ ភូមិក្តីតាកុយ សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឬតាមរយៈទូរស័ព្ទលេខ **(៨៥៥) ៩៨ ៨៨៩ ៨៨៩ ឬ (៨៥៥) ៧៨ ៨៦ ៨៦ ៩៨**។

ថ្ងៃពុធ ១៤កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
**គណៈកម្មការជ្រើសរើសសមាជិកគ.ប.ក.**
**ដែលជាបុគ្គលឯករាជ្យ**

## ពាក្យស្នើសុំធ្វើជាសមាជិកគ.ប.ក. ដែលជាបុគ្គលឯករាជ្យ

### ក. ប្រភេទសមាជិកគ.ប.ក. ដែលជាបុគ្គលឯករាជ្យ

ចូរគូសសញ្ញា ✓ នៅក្នុងប្រអប់ ☐ ចំពោះប្រភេទសមាជិក**គ.ប.ក.** ដែលជាបុគ្គលឯករាជ្យដែលអ្នកដាក់ពាក្យស្នើសុំជ្រើសរើស៖

☐ អតីតចៅក្រម

☐ បុគ្គលដែលមានចំណេះដឹងនិងបទពិសោធផ្នែកច្បាប់

☐ បុគ្គលដែលមានចំណេះដឹងនិងបទពិសោធផ្នែកសេដ្ឋកិច្ច

### ខ. ព័ត៌មានផ្ទាល់ខ្លួន

ឈ្មោះ៖..............................................ឈ្មោះជាអក្សរឡាតាំង៖..............................................

ភេទ៖..........................ជនជាតិ៖..................................សញ្ជាតិ៖...........................................

ថ្ងៃខែឆ្នាំកំណើត៖................................................ អាយុ៖................................................

ទីកន្លែងកំណើត៖...................................................................................................

.......................................................................................................................

អាសយដ្ឋានបច្ចុប្បន្ន៖............................................................................................

.......................................................................................................................

.......................................................................................................................

លេខទូរស័ព្ទ៖........................................................................................................

អាសយដ្ឋានអេឡិចត្រូនិក(Email)៖.............................................................................

មុខរបរបច្ចុប្បន្ន៖...........................................អង្គភាព៖...........................................

អាសយដ្ឋានអង្គភាព៖..............................................................................................

.......................................................................................................................

.......................................................................................................................

## គ. កម្រិតវប្បធម៌ និងប្រវត្តិនៃការសិក្សា

- ពីឆ្នាំ...........ទៅឆ្នាំ.........................ទទួលបានសញ្ញាបត្រ................................................... ពី...........................................................................................................................។
- ពីឆ្នាំ...........ទៅឆ្នាំ.........................ទទួលបានសញ្ញាបត្រ................................................... ពី...........................................................................................................................។
- ពីឆ្នាំ...........ទៅឆ្នាំ.........................ទទួលបានសញ្ញាបត្រ................................................... ពី...........................................................................................................................។
- ពីឆ្នាំ...........ទៅឆ្នាំ.........................ទទួលបានសញ្ញាបត្រ................................................... ពី...........................................................................................................................។
- ពីឆ្នាំ...........ទៅឆ្នាំ.........................ទទួលបានសញ្ញាបត្រ................................................... ពី...........................................................................................................................។
- ពីឆ្នាំ...........ទៅឆ្នាំ.........................ទទួលបានសញ្ញាបត្រ................................................... ពី...........................................................................................................................។
- ពីឆ្នាំ...........ទៅឆ្នាំ.........................ទទួលបានសញ្ញាបត្រ................................................... ពី...........................................................................................................................។

## ឃ. បទពិសោធន៍វិជ្ជាជីវៈ

- ពីឆ្នាំ...........ទៅឆ្នាំ.........................បានធ្វើការជា........................................................... នៅអង្គភាព...............................................................................................................។
- ពីឆ្នាំ...........ទៅឆ្នាំ.........................បានធ្វើការជា........................................................... នៅអង្គភាព...............................................................................................................។
- ពីឆ្នាំ...........ទៅឆ្នាំ.........................បានធ្វើការជា........................................................... នៅអង្គភាព...............................................................................................................។
- ពីឆ្នាំ...........ទៅឆ្នាំ.........................បានធ្វើការជា........................................................... នៅអង្គភាព...............................................................................................................។
- ពីឆ្នាំ...........ទៅឆ្នាំ.........................បានធ្វើការជា........................................................... នៅអង្គភាព...............................................................................................................។
- ពីឆ្នាំ...........ទៅឆ្នាំ.........................បានធ្វើការជា........................................................... នៅអង្គភាព...............................................................................................................។
- ពីឆ្នាំ...........ទៅឆ្នាំ.........................បានធ្វើការជា........................................................... នៅអង្គភាព...............................................................................................................។

**ខ. ការប្រកាស/ការអះអាង**

១. ខ្ញុំសូមធានាទទួលខុសត្រូវចំពោះមុខច្បាប់ថា ព័ត៌មានដែលបានបំពេញនៅក្នុងពាក្យស្នើសុំនេះនិងឯកសារភ្ជាប់ ពិតជាត្រឹមត្រូវប្រាកដដូចការអះអាងមែន។

២.ក្នុងករណីដែលត្រូវបានជ្រើសរើសជាសមាជិកគ.ប.ក. ដែលជាបុគ្គលឯករាជ្យ ខ្ញុំសុខចិត្តទទួល និងអនុវត្ត តួនាទី និងការងារជាសមាជិកគ.ប.ក. ដែលជាបុគ្គលឯករាជ្យ ដូចដែលមានកំណត់ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ថ្ងៃ.....................ខែ.....................ឆ្នាំ.......................... ព.ស.....................

ធ្វើនៅ.........................ថ្ងៃទី.............ខែ..................ឆ្នាំ.........................

ហត្ថលេខា

ឈ្មោះ៖.................................

**<u>ចំណាំ</u>៖** សូមភ្ជាប់មកជាមួយពាក្យស្នើសុំនេះផងដែរនូវឯកសារពាក់ព័ន្ធដូចខាងក្រោម៖

| | | |
|---|---|---|
| ១. | រូបថត ៤ x ៦ | ៣ សន្លឹក |
| ២. | ប្រវត្តិរូបសង្ខេប | ១ ច្បាប់ |
| ៣. | លិខិតថ្កោលទោស | ១ ច្បាប់ |
| ៤. | អត្តសញ្ញាណបណ្ណ សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ(ថតចម្លង) | ១ ច្បាប់ |
| ៥. | លិខិតអនុសាសន៍ | ១ ច្បាប់ |
| ៦. | លិខិតបញ្ជាក់ទីលំនៅ | ១ ច្បាប់ |

៧. ឯកសារដែលជាភស្តុតាងបញ្ជាក់អំពីចំណេះដឹង និងបទពិសោធការងារ

៨. លិខិតពិពណ៌នាអំពីគោលបំណង ការបង្ហាញពីចំណេះដឹង សមត្ថភាព ជំនាញ និងបទពិសោធដែលសមស្របគ្រប់គ្រាន់សម្រាប់បំពេញមុខងារជាសមាជិក**គ.ប.ក.** ដែលជាបុគ្គលឯករាជ្យ ព្រមទាំងការយល់ដឹង និងចក្ខុវិស័យអំពីគោលនយោបាយក្នុងការប្រកួតប្រជែង កិច្ចការពារអ្នកប្រើប្រាស់ និង វិស័យពាក់ព័ន្ធរបស់ខ្លួន មិនលើសពី១០ទំព័រ។